ឯកសារស្នើសុំជំនួយគតិយុត្តិដោយឥតគិតថ្លៃ៖



- លិខិតស្នើសុំជំនួយគតិយុត្តិ (តាមគំរូដែលផ្តល់ដោយអង្គការអនុវត្តជំនួយគតិយុត្តិ ឬទាញយកពី គេហទំព័រសេវាសាធារណៈជាតិ សម្រាប់នីតិវិធីស្នើសុំជំនួយគតិយុត្តិ លេខកូដ 2.0000829)។
- លិខិតបញ្ជាក់ថាស្ថិតក្នុងក្របខ័ណ្ឌទទួលបានជំនួយគតិយុត្តិ (ឧទាហរណ៍៖ វិញ្ញាបនបត្រគ្រួសារក្រីក្រ គ្រឿងឥស្សរិយយស មេដាយ...)។
- ឯកសារនិងលិខិតពាក់ព័ន្ធនឹងកិច្ចការដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ (ឧទាហរណ៍៖ វិញ្ញាបនបត្រសិទ្ធិប្រើប្រាស់ដីធ្លីជាដើម)។

ព័ត៌មានទាក់ទងដើម្បីស្នើសុំជំនួយគតិយុត្តិក្នុងការដោះស្រាយទ្រព្យសម្បត្តិ នៅពេលលែងលះ៖

- មជ្ឈមណ្ឌលជំនួយគតិយុត្តិរដ្ឋ ស្ថិតក្រោមមន្ទីរយុត្តិធម៌រាជធានី ខេត្ត និងក្រុងដែលស្ថិតក្រោមមជ្ឈិម។
- អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាផ្នែកច្បាប់ ដែលចូលរួមអនុវត្តជំនួយគតិយុត្តិ។

:អស់យដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានប្រកាសជាសាធារណៈនៅ៖

- **គេហទំព័រនីតិកម្មជាតិ**
  https://phapluat.gov.vn/
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់ក្រសួងយុត្តិធម៌**
  https://dstrogiupphaply.moj.gov.vn/all/searchOrganization
- **គេហទំព័រព័ត៌មានអេឡិចត្រូនិកស្តីពីជំនួយគតិយុត្តិនៅប្រទេសវៀតណាម**
  https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់មន្ទីរយុត្តិធម៌នៅមូលដ្ឋាន**

លោកអ្នកអាចទាក់ទងតាមមធ្យោបាយខាងក្រោម ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖

ខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីជំនួយគតិយុត្តិ

1800 1234

(Cước gọi miễn phí)

ទាញយកកម្មវិធីទូរស័ព្ទចល័តស្តីពីជំនួយគតិយុត្តិ

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ Android

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ iOS

BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិក្នុងការដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ

TRỢ GIÚP PHÁP LÝ



ការលែងលះ និងការដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ៖

• ការលែងលះគឺជាការបញ្ចប់ទំនាក់ទំនងជាប្តីប្រពន្ធ តាមរយៈ សាលក្រម ឬសេចក្តីសម្រេច ដែលមានអានុភាពតាមផ្លូវច្បាប់របស់តុលាការ។

• ទ្រព្យសម្បត្តិនៅពេលលែងលះ រួមមាន៖ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និង ទ្រព្យសម្បត្តិដោយឡែករបស់ប្តី/ប្រពន្ធ (ប្រសិនបើមាន)។

• ដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ៖

• ទ្រព្យសម្បត្តិរួម ត្រូវបានផ្តល់អាទិភាពដោះស្រាយតាមការព្រមព្រៀងរបស់ប្តីប្រពន្ធ។
•ក្នុងករណីដែលប្តីប្រពន្ធមិនអាចឈានដល់ការព្រមព្រៀងបាន តុលាការដែលមានសមត្ថកិច្ច នឹងពិនិត្យដោះស្រាយស្របតាមបទប្បញ្ញត្តិច្បាប់។

• ការបែងចែកទ្រព្យសម្បត្តិរួម បានអនុវត្តដោយវត្ថុជាក់ស្តែង។ ប្រសិនបើមិនអាចបែងចែកដោយវត្ថុជាក់ស្តែង គឺចែកតាមតម្លៃសមមូល។

• ទ្រព្យសម្បត្តិដោយឡែករបស់ភាគីនីមួយៗ នៅតែជាកម្មសិទ្ធិរបស់បុគ្គលនោះ លើកលែងតែក្នុងករណីដែលទ្រព្យសម្បត្តិដោយឡែក ត្រូវបានបញ្ចូលទៅក្នុងទ្រព្យសម្បត្តិរួម ឬមានការព្រមព្រៀងផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់។

(មាត្រា ៥៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ)



សមត្ថកិច្ចក្នុងការដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ៖

- តុលាការប្រជាជនតំបន់មានសមត្ថកិច្ចដោះស្រាយសវនាការសាលាដំបូង នូវតម្រូវការស្នើសុំលែងលះ និងទ្រព្យសម្បត្តិនៅពេលលែងលះ។
- តុលាការប្រជាជនថ្នាក់ខេត្ត មានសមត្ថកិច្ចជំនុំជម្រះនៅសវនាការសាលាឧទ្ធរណ៍ ចំពោះសាលក្រម សេចក្តីសម្រេចនៅសវនាការសាលាដំបូង ដែលត្រូវបានប្តឹងឡើងឧទ្ធរណ៍ ឬតវ៉ាតាមនីតិវិធីស្របតាមបទប្បញ្ញត្តិ។

(កថាខណ្ឌទី ២ និងកថាខណ្ឌទី ៤ មាត្រា ១ នៃច្បាប់វិសោធនកម្ម និងបំពេញបន្ថែមមាត្រាមួយចំនួននៃក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់នីតិវិធីរដ្ឋបាល ច្បាប់យុត្តិធម៌អនីតិជន ច្បាប់ក្ស័យធន និងច្បាប់ផ្សះផ្សា ចរចានៅតុលាការ)

អ្នកដែលទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃ

នៅពេលមានបញ្ហាផ្លូវច្បាប់ក្នុងកិច្ចការដោះស្រាយទ្រព្យសម្បត្តិក្នុងពេលលែងលះ អ្នកដែលស្ថិតក្នុងករណីដូចខាងក្រោម មានសិទ្ធិទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃ៖

- អ្នកមានសគុណចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងក្របខណ្ឌគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានស្ថានភាពសេដ្ឋកិច្ច - សង្គមលំបាកជាពិសេស។
- អ្នកដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ក្នុងករណីជាអ្នកត្រូវចោទប្រកាន់ អ្នកត្រូវបានស្នើឲ្យប្តឹង អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកចុងចោទ ជនរងគ្រោះ សាក្សី អ្នកដែលកំពុងស្ថិតក្រោមការអនុវត្តវិធានការដោះស្រាយបង្វែរទិស និងជាទណ្ឌិតក្នុងនីតិវិធីព្រហ្មទណ្ឌ។
- អ្នកចុងចោទដែលស្ថិតក្នុងក្របខ័ណ្ឌគ្រួសារបៀតក្រីក្រ។
- អ្នករងគ្រោះអ្នកដែលកំពុងស្ថិតក្នុងដំណើរការកំណត់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំរួមដំណើរជាមួយស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីមួយក្នុងចំណោមករណីដូចខាងក្រោមនេះ មានការលំបាកអំពីហិរញ្ញវត្ថុ៖ i) ឪពុកបង្កើត ម្តាយបង្កើត ប្តី ប្រពន្ធ កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ក្នុងការចិញ្ចឹមបីបាច់យុទ្ធជនពលីកាលពីនៅតូច; ii) អ្នកដែលរងផលប៉ះពាល់ដោយសារធាតុពុលពណ៌ទឹកក្រូច; iii) មនុស្សចាស់; iv) ជនមានពិការភាព; v) ជនរងគ្រោះក្នុងករណីអំពើហិង្សាគ្រួសារ; vi) អ្នកជ្រាប HIV។

លក្ខខណ្ឌលំបាកអំពីហិរញ្ញវត្ថុរបស់អ្នកទទួលជំនួយគតិយុត្តិ គឺជាមុខសញ្ញាស្ថិតក្នុងគ្រួសារបៀតក្រីក្រ ឬជាមុខសញ្ញាដែលកំពុងទទួលប្រាក់ឧបត្ថម្ភសង្គមប្រចាំខែ តាមបទប្បញ្ញត្តិនៃច្បាប់។



សេវាជំនួយគតិយុត្តិដោយឥតគិតថ្លៃរួមមាន៖

ការប្រឹក្សាផ្នែកច្បាប់ ការចូលរួមក្នុងនីតិវិធី និងតំណាងក្រៅនីតិវិធី ក្នុងគ្រប់វិស័យ រដ្ឋប្បវេណី ព្រហ្មទណ្ឌ រដ្ឋបាល អាពាហ៍ពិពាហ៍ និងគ្រួសារ... (លើកលែងតែវិស័យ អាជីវកម្ម និងពាណិជ្ជកម្ម)។ ជាក់ស្តែង ក្នុងកិច្ចការដោះស្រាយទ្រព្យសម្បត្តិក្នុងពេលលែងលះ អ្នកទទួលបានជំនួយគតិយុត្តិ នឹងត្រូវបានផ្តល់ជូននូវសេវាជំនួយគតិយុត្តិ ដូចខាងក្រោម៖

ការផ្តល់ប្រឹក្សាច្បាប់៖

បានភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីអនុវត្តជំនួយនិតិវិធីការពារសិទ្ធនិងផលប្រយោជន៍ស្របច្បាប់ ក្នុងដំណើរចូលរួមនិតិវិធីនៅតុលាការដើម្បីដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ។





ការចូលរួមក្នុងនិតិវិធី៖

បានភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីអនុវត្តជំនួយគតិយុត្តិ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ធ្វើជាតំណាង និងជំនួស ក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទទួលបានជំនួយគតិយុត្តិ នៅចំពោះមុខស្ថាប័នរដ្ឋដែលមានសមត្ថកិច្ច ក្នុងសំណុំរឿងដោះស្រាយទ្រព្យសម្បត្តិនៅពេលលែងលះ។

ការតំណាងក្រៅនីតិវិធី៖

ត្រូវបានភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីដែលអនុវត្តជំនួយគតិយុត្តិ ធ្វើជាតំណាង និងជំនួសមុខឲ្យអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ច នៅចំពោះមុខស្ថាប័នរដ្ឋមានសមត្ថកិច្ច ក្នុងកិច្ចការដោះស្រាយទ្រព្យសម្បត្តិក្នុងពេលលែងលះ។

